ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំសាធារណរដ្ឋកូរ៉េ

**ឯកអគ្គរាជទូត**

*លេខៈ ១៩៨.១១ សកស*

*សេអ៊ូល, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១*

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុៈ** *សភាពការណ៍សេដ្ឋកិច្ចទូទៅ នៃសាធារណរដ្ឋកូរ៉េ និងទំនាក់ទំនង កម្ពុជា-កូរ៉េ ឆ្នាំ ២០១១*

**តាមរយៈ ឯកឧត្តមឯកអគ្គរាជទូត**

*ខ្ញុំបាទមានកិត្តិយស សូមគោរពជំរាបជូន* **ឯកឧត្តមទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា សភាពការណ៍សេដ្ឋកិច្ច នៃប្រទេសកូរ៉េ នាបច្ចុប្បន្នកាលនេះ បាននិងកំពុង តែមានសញ្ញាវិជ្ជមាន ដោយសេដ្ឋកិច្ចមានកម្លាំងងើបស្ទុះឡើងវិញ ជាកត្តាធ្វើអោយកូរ៉េ សំរេចបាននូវសម្មិទ្ធិផលធំៗ ជាច្រើននាឆ្នាំ ២០១០ កន្លងមក និងដើមឆ្នាំ ២០១១។ សេដ្ឋកិច្ចរីកចំរើនឡើង ទាំងប្រទេសអ្នកមាន និងប្រទេសកំពុងអភិវឌ្ឍន៏ ធ្វើអោយមានការកើនឡើងនូវតម្រូវការ ទាំងក្នុងនិងក្រៅប្រទេស កំណើនលើការផលិតនិងផ្គត់ផ្គង់ ។ ចំណុចសំខាន់ ដែលអ្នកសំរបសំរួលគោលនយោបាយកូរ៉េ ព្យាយាមទប់ស្កាត់ការកើនឡើងអតិផរណា ដើម្បីធ្វើអោយមានស្ថេរភាពតម្លៃ ជៀសវាងផលប៉ះពាល់ខ្លាំង ដល់ប្រជាជនដែលមានចំណូល ទាបនិងមធ្យម ។*

*ពាណិជ្ជកម្មទ្វេទិស របស់កូរ៉េ ក្នុងឆ្នាំ ២០១១ នេះ រំពឹងគិតថា នឹងឈានទៅដល់បរិមាណ 1.000 Billion USD ។*

*កំណើនសេដ្ឋកិច្ច ស.កូរ៉េ នាឆ្នាំ ២០១០ កន្លងមក មានកំរិតប្រមាណជា 6.2% ហើយនៅឆ្នាំ ២០១១ នេះ អ្នកសេដ្ឋកិច្ច កូរ៉េរំពឹងគិតថា ឆ្នាំ ២០១១ មានសន្ទុះកើនឡើងប្រមាណជា 5% តែដោយស្ថានភាពមិនសូវជាល្អប្រសើរ នាឆមាសទី ២ ដោយតម្រូវការជាសកល មាននិន្នាការថយចុះ ការកើនឡើងអតិផរណា ព្រមពេលជាមួយគ្នានោះដែរ វិបត្តិបំណុលនៅតំបន់អឺរ៉ូ នៅមិនទាន់បានធូរស្រាលនៅឡើយ រួមជាមួយបញ្ហាអវិជ្ជមានផ្សេងទៀត ធ្វើអោយអ្នកសេដ្ឋកិច្ចកូរ៉េរំពឹងគិតជាថ្មីឡើងវិញថា ឆ្នាំ ២០១១ មានសន្ទុះកើនឡើងប្រមាណជា 4.0 % ទៅ4.8% ។*

**សភាពការណ៍សេដ្ឋកិច្ចទូទៅ ឆ្នាំ ២០១១ និងទំនាក់ទំនងទ្វេភាគី កម្ពុជា-កូរ៉េ** *ដូចតទៅ :*

***I. កម្ពុជា នាំចេញទៅកូរ៉េ ប្រចាំខែ នាឆ្នាំ ២០១០ ប្រៀបធៀបឆ្នាំ ២០១១***

*តម្លៃគិតជា ១០០០ ដុល្លារ*

*ប្រភពពត៌មាន សមាគមពាណិជ្ជកម្មអន្តរជាតិ នៃប្រទេសកូរ៉េ*

Royal Embassy of Cambodia
653-110 Hannam-dong
Yongsan-gu, Seoul 140-887
Republic of korea

Tel : 82 2 3785 1041
Fax : 82 2 3785 1040
E-mail : camboemb@korea.com




*កម្ពុជា នាំចេញទៅ ស.កូរ៉េ ពីខែមករា ដល់ខែ សីហា ឆ្នាំ ២០១១*

*កម្ពុជា នាំចេញទៅ ស.កូរ៉េ ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០១០*

*យោងតាម តារាងនិងទូរលេខ ដូចមានជំរាបជូនខាងលើៈ រយៈពេល ០៨ ខែ ពីមករា ដល់ សីហា នាឆ្នាំ ២០១១ កន្លងមកនេះ **ទំនិញនាំចេញ ពីកម្ពុជា មកប្រទេសកូរ៉េ** មានទឹកប្រាក់ 51,001,000 US$ កំណើនមធ្យមភាគ កើនឡើងចំនួន 82.3% ប្រៀបធៀប រយៈពេល ៨ ខែដូចគ្នា នាឆ្នាំ ២០១០ ដែលមានទឹកប្រាក់ ចំនួន 27,977,000 US$ ។*

*កំណើនដែលគួរអោយកត់សំគាល់ គឺការនាំចេញ របស់កម្ពុជា មកស.កូរ៉េ រយៈ៨ខែ ឆ្នាំ ២០១១ នេះ ចំនួន 51,001,000 US$ មានបរិមាណលើស ការនាំចេញរយៈពេល ពេញមួយឆ្នាំ ២០១០ ដែលមានទឹកប្រាក់ ចំនួន 43,445,000 US$.*

## II. បរិមាណនាំចេញ ពីកម្ពុជា ទៅ ស.កូរ៉េ ប្រចាំឆ្នាំ ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១១ គិតជាពាន់ ដុល្លារ អាមេរិក

